# ជួបដំបូង

សូម្បីតែនៅក្នុងអ័ព្ទដ៏ត្រជាក់ ហើយមិនទាន់ចាកចេញពីកំពង់ទឹកខេត្តកណ្ដាលនៅឡើយផង ក៏ទិដ្ឋភាពដងទន្លេមួយនេះ ពិតជាស្អាតជាងការគិតរបស់ Kemal។ គេផ្ទេចភ្នែកមួយចំហៀង ផ្ទៀងស្មាមាំធំដ៏ស្រស់សង្ហា ដែលស្រីៗភាគច្រើនស្រមៃចង់ខ្ចីយកមកកើយ កំដរភាពតឹងតែងក្នុងឆាកជីវិត។ ម្រាមដៃបុរសបន្តសង្កត់ចុចប៊ូតុងកាមេរ៉ាផ្តិតយកទិដ្ឋភាពនានាយ៉ាងត្រជាក់ចិត្តមិនគិតដល់រឿងអ្វីទាំងអស់ ។

ស្នាមញញឹមគេ លេចឡើងបន្តបន្ទាប់ មិនចេះឆ្អែតឆ្អន់សោះ ក៏ជាស្ថានភាពដែលមនុស្សជិតស្និទ្ធនានាខានបានឃើញយូរណាស់មកហើយ។

ដៃឆ្វេងស្តាំទាំងឡាយបានត្រឹមក្រឡេកមើលមកពីចម្ងាយ ទោះបីសុភមង្គល Kemal ជារឿងធំតែមួយគត់ដែលពួកគេចង់ឃើញ។ ម្នាក់ៗដឹងថាយប់នេះពួកគេមុខតែមានសំណាងបានឃើញទិដ្ឋភាពកម្រនៃដែនទឹកខ្មែរ ក្រោមស្នាដៃថតរូបកម្រិតពានពិភពលោក ដែលម្ចាស់រូបថតមិនងាយនឹងធ្វើទេប្រសិនគេមិនមែនកំពុងតែមានសេចក្តីសុខផ្លូវចិត្ត។

Kemal តែងតែផ្តល់ជូនពិភពលោកនូវអ្វីដែលកម្ពុជាមាន ហើយមិនសូវបានអ្នកណាមើលស្គាល់ឬឱ្យតម្លៃ លាតត្រដាងចេញមកឱ្យចំលក្ខណៈពិសេសនីមួយៗឡើយ។ គេមិនសូវនិយាយតែរូបថតមួយសន្លឹកៗរបស់បុរសខ្មែរម្នាក់នេះតែងតែអាចនិយាយជំនួសនូវអត្ថន័យរាប់ពាន់។

ពន្លឺព្រះអាទិត្យហូរចូលមកតាមបង្អួចបន្ថែម កម្ដៅលើកំភួនដៃដ៏រឹងមាំនៃរាងកាយប្រុសស្អាតកម្ពុជាជាមួយ និងកំស្ទួលដង្ហើមពេញដោយភាពមាំទាំរបស់គេ។

ហេតុអ្វីភ្លាមៗនោះ ដង្ហើមគេហាក់បង្អង់ស្ងប់សឹងតែអាចលែងដកបាន?

ម្រាមដៃរបស់ Kemal នៅទ្រឹង ភ្នែកស្តាំនៅផ្ទេចពន្លែងចក្ខុឆ្វេងបាញ់មួយទំហឹងទៅលើច្រាំងទន្លេខៀវស្រងាត់អមលម្អដោយកម្រាលចម្ការថ្នាំបៃតងស្រស់។

មនុស្សស្រីរាងរាវ ដំណើរល្វតល្វៃ ញែកកាត់ផ្ទៃចម្ការវែងអន្លាយរាងដូចស្រកានាគក្រាលគ្រប់ច្រាំងនាទិសបស្ចិម ។ នាងបានឆក់យកដង្ហើមជាងថតកម្សត់ស្នេហ៍ទៅបាត់។

ដៃនាងកាន់វ៉ាលិស ដៃម្ខាងទៀតត្រកងបាច់ផ្កា ។ សំពត់ពណ៌លឿងទុំដែលប៉ោងកម្រើកក្រោមអំណាចវាយោដងទន្លេ បង្ហាញថានារីនេះមានចេតនាឱ្យរូបមួយផ្ទាំងរបស់នាងត្រូវបានបង្អួតនាវិចិត្រសាលធំ Burj Khalifa ច្បាស់ណាស់។

ស្នាមញញឹមស្រស់សង្ហាបានបើកផ្លូវមកសិន មុនពេលម្ចាស់វាដកដង្ហើមយូរហើយចុចយក។។

Kemal ប្រើភ្នែកមួយចំហៀង ម្រាមតែមួយ តែបេះដូងនាយបានស្រមៃគ្រប់យ៉ាង លម្អិត ជ្រាលជ្រៅ ទាន់ហន់ ថាអ្វីខ្លះនឹងកើតមានលើលោកនេះប្រសិនគេកំពុងមាននាងក្នុងលង្វែកទ្រូង។

លើសពីសម្រស់ធម្មជាតិដែលភ្នែកធម្មតាៗក្រឡេកឃើញ បុរសនេះសម្គាល់ ភាពហត់នឿយលើទឹកមុខនារីតូច ដែលដាមញើសលើថ្ងាស សហ្មត់ សក់ពណ៌ទង់ដែងក្រាលគ្រប់លើខ្នង រោលរាលចុះឡើងតាមចង្វាក់ដំណើរចុះច្រាំង ចង្កេះនាងតូចស្ដួចរលាក់ម្ដងឆ្វេងមកស្ដាំ ជើងទាំងគូវែងលលៃ រង្វង់មុខថ្កាមខ្លា មិនស្រួចមិនV បបូរមាត់ទ្រលុកពេញរលើប អាចឱ្យ Kemal ឃើញភ្លែតស្រមៃភ្លាមដល់ផ្នែកទន់ជ្រាយដែលលាក់ក្រោមចង្កេះនាង ប្រាកដណាស់ នាងមានកម្លាំងទាក់ទាញមនុស្សភេទផ្ទុយឱ្យរោលរាលស្រមើស្រមៃទាំងមិនចាំបាច់អាក្រាត។

«Sexy Lady»

គេភ្លាត់មាត់តិចៗ ដែលមិនអាចទ្រាំបាន ខណៈកម្លាំងសាច់ដុំពេញរាងកាយហាក់ចេះកម្រើក រឹងមាំឡើងៗ ដូចត្រូវសណ្ដំដោយមន្តអាគមណាមួយជំរុញឱ្យសសៃសសូងទាំងរាប់ពាន់ផ្នែក រួមគ្នាស្ទុះស្ទាស្ទាហាប់ បង្កជាអារម្មណ៍ ចង់ឃើញ ចង់គិត ចង់បាន ចង់គ្រប់គ្រង។

ទូកឆ្នោតមួយ បង្ហាញឡើងពីមុខកាណុងធំមាំនៃប្រុសកម្លោះ។

«shit»

អ្នកនេសាទប្រុសៗមួយក្រុមបានសែងទូកឆ្នោតវែងមួយមកដល់។ សកម្មភាពតាមទម្លាប់នៃភូមិអ្នកជលសា មិនដឹងឯណាថា កំពុងបានរាំងខ្សែចក្ខុប្រុសស្អាតដែលផ្ចង់ស្រមៃឃើញស្រីល្អដោយកាមារម្មណ៍។

នាយបង្អង់ម្រាមសំចតលើប៊ូតុងហើយងើបមុខមករង់ចាំដោយអន្ទះសារ។ ទូកវែងហើយធ្ងន់។ ទម្រាំជំនិះនេះចេញផុត នាងបាត់ស្រមោលទៅហើយ! ឃើញឬនៅ?

អស់អារម្មណ៍!

ទិដ្ឋភាពស្រស់បំព្រងក្លាយជាសៅហ្មងពេលគ្មានស្រីថ្លៃ។

គេចុចប៊ូតុងបិទហើយទម្លាក់ដៃ។

ទាំងដើមទ្រូងក្រាស់ធំ បន្ទួរដង្ហើមយូរ ចង់បញ្ចេញចោលភាពតានតឹងដែលត្រូវបានផ្ដល់សុភមង្គលមកមួយប៉ប្រិចភ្នែកក៏រលាយអសារ។ តាមថា ទិដ្ឋភាពក្រុមអ្នកនេសាទដែលខ្លះស្លៀកពេញលេញ ខ្លះ

ដោះអាវទេ ស្លៀកតែសារ៉ុងសូត្រ ក៏អាចក្លាយទៅជាផ្ទាំងរូបថតជីវិតពិតដ៏កម្រឃើញនាដង ទន្លេសាបតំបន់ត្រពិច តែមនុស្សគ្មានអារម្មណ៍ទៅហើយ។

គេងាកទៅរកដងទន្លេក្រែងជំនោរនិងបក្សាលើកម្រាលទឹកអាចបន្ទូរចិត្តមកវិញបានខ្លះ តែ! វាគ្មានប្រយោជន៍ទេ។ សម្រើបបេះដូងដែលបានរលត់ទៅហើយ ដាស់មកវិញ មិនដែលបានភ្លាមៗឯណា?

«អ្ហូយ ហាត់ម្លេះ!»

គេក្រឡេកមកវិញដោយស្វ័យប្រវត្តិនិមិត្តតែឮសំឡេងស្រទន់ក្អិកក្អក់។ តាមថា Kemal មានប្រតិកម្មយឺតណាស់ ព្រោះច្រើនឆ្នាំមកនេះ ចិត្តនាយត្រូវស្ងប់ដូចសមុទ្រឥតរលក ឬអាចថា វាលសោះខ្យល់ មិនដឹងហេតុអី ត្រឹមពាក្យបីម៉ាត់ គេបែរជាសកម្មរហ័សហួសស្មាន។

លើទូកនេះគ្មានមនុស្សស្រីទេ!

នេះជាសំឡេងសម្ងាត់ចោទសួរក្នុងខួរក្បាលនរះយើង។

តាមកញ្ចក់មើលនៅខាងក្រោយខ្នង គេឃើញស្រមោលស្រាលពណ៌លឿង។ ការលោតរំជួលស្រិបៗនៃបេះដូងបានខ្សឹបប្រាប់គេថា ព្រះកំពុងប្រទានអ្វីមួយពិតហើយ។

មនុស្សស្រីលើច្រាំងទន្លេបានចូលមកដល់ជិតបង្កើយ។

ហើយចៃដន់ម្លេះហ្ន៎?

នាងចុះមកជាមួយសំណុំផ្កា ដៃយួរវ៉ាលិស និងទឹកមុខរលះរលាំងចុងក្រោយ ភ្នែកស្រីមកទើរចំប្រុសស្អាតដែលកំពុងបែរក្រោយផ្ទឹងនៅពីមុខនាង។

នាងមឹងម៉ាំង.....

ទេវបុត្រមកពីទិសខាងណានៀក?

ស្រីសំពត់លឿង បានបោះបង់ចោលទឹកមុខអន្ទះសាហាត់នឿយ ហើយខំរៀបឫករៀបទឹកមុខភ្លាមៗ ម្តងចង់ញញឹម ម្តងចង់ធ្វើមុខស្មើ បណ្តាលឱ្យបបូរមាត់សិចស៊ី រេកម្រើកចុះឡើងទាំងគ្មានសំឡេង។

អត់ដឹងខាងបុរសចំហមាត់លង់ទេ?

នាងអៀននឹងពន្លឺភ្នែកជ្រាលជ្រៅរបស់នាយ។

ភាពគ្មានសំឡេងរវាងមនុស្សពីនាក់ ដែលហាក់ស័ក្តិសមគ្មានទាស់ បានបណ្តាលឱ្យនាងបង្វៃរភ្នែកចេញទាំងចិត្តមិនយល់ស្របព្រោះនៅនឹកស្តាយ។

ជាមួយនោះ ស្រីតូចក៏បានក្រឡេកទៅឃើញកាមេរ៉ា ដែលគេកំពុងក្ដោបក្នុងប្រអប់ដៃធំមាំ ទម្លាក់ដៃក្បែរជើងស្ដាំដ៏មាំសង្ហា។ ខោខូវប៊យរបស់គេ ពិតជាកំពុងតុបតែងបុរសនេះពីលើដល់ក្រោមស្អាតសង្ហាដូចតួកុនក្នុងរឿង...រឿងអីមិនដឹងទេ ដឹងតែ ជាតួប្រុសពិតណាស់ គឺតួឯកមែនហើយ។

នេះជាទូកឯកជនសោះហ្នឹង ខ្យល់ព្រេងនិស្ស័យអីបក់នាំនាងឡើងមកបាន?

គេគិតក្នុងបេះដូងជាមួយការលេចឡើងសន្សឹមៗនៃស្នាមញញឹមស្វាគមន៍ភ្ញៀវពិសេសដែលជួបដោយឥតព្រាងទុក។

ពីក្រោយខ្នងស្រីស្រស់ចំណាប់ ប្រុសៗមាឌមាំពីរនាក់រត់ឡើងមកដល់ ។ កាយវិការពួកគេស្រាលស្មើកស័ក្ដិសមជាអង្គរក្សដ៏ចំណាន ក៏ប៉ុន្ដែគេឡើងមកមិនត្រូវពេលទេ។ ម្ចាស់ទូកមិនបានចង់ឱ្យគេបណ្ដេញនាងចេញទៅវិញឡើយ។

ម្រាមដៃឆ្វេងប្រុសស្អាតផ្ដុំចូលគ្នាហើយគ្រវាសជាសញ្ញាសម្ងាត់ឱ្យកងការពារដកថយ...

សែនមហាយល់ចិត្តនាយថៅហ្វាយ អង្គរក្ស ដែលស្មានថាកំពុងសាងកំហុស ធ្វេសប្រហែសបណ្ដោយទ្វារឱ្យមនុស្សមិនស្គាល់អត្តសញ្ញាណជ្រែកឡើងមកបានដឹងអីពេលនេះ បែរជាត្រូវបានពេញចិត្តទៅវិញ?

នៅលើនេះសល់តែយើងពីរនាក់។

បុរសបានឱកាសញញឹមស្វាគមន៍នាង ម្យ៉ាងចង់បង្អួតសម្រស់ ដែលទំនុកចិត្តនេះលែងមានជាយូរណាស់មកហើយ។

ស្រីស្អាតមិនបានសម្លឹងនាយវិញទេ។ នាងអៀនប្រៀនមិនមែនគេមិនដឹងទេ ។ ប្រុសស្អាតសម្លឹងសកម្មភាពនាងដែលដាក់វ៉ាលិសថ្មមៗលើកម្រាលដែកនែកប៉ាល់ទំនើបហើយដៃម្ខាងគ្រវាសសក់យ៉ាងរហ័សទៅក្រោយបញ្ចេញផែនស្មារាវស្រឡូន ក្រោមអាវយឺតស។ បុរសដឹងថា នាងកំពុងយកចិត្តទុកដាក់ឡើងវិញអំពីរូបរាងសម្រស់ពេលជួបជំពើបនឹងវត្តមានខ្លួន។

គេដើរចូលមកសន្សឹមៗ ក្នុងលក្ខណៈសុភាពបុរសកំពុងឆ្លៀតឱកាសទាញពិន្ទុ។ ស្រីស្អាតនៅនឹងមុខបើធ្វើព្រងើយមិនដឹងខ្លួន មានតែតួកុហកក្នុងរឿងល្ខោនឡូយពីដំបូង ចុងក្រោយរណបគេដដែល ចាប់ផ្ដើមតែម្ដងកុំឱ្យខាតពេល មិនអ៊ីចឹង?

«ខ្ញុំជួយដាក់វ៉ាលិសឡើងលើ!»

គេនិយាយទៅកាន់ត្រៀវពិសេសធ្វើនាងភាន់បន្តិច ជាមួយនឹងកែវភ្នែកទាំងសងមូលក្លំខំប្រឹងទប់ចិត្ត រំភើប។ ត្រូវឆ្លើយជាមួយប្រុសស្អាតចរិតសុភាពរបៀបណាសមនៀក? គួរចាប់ផ្ដើមពីកន្លែងណា?

កន្លែងហ្នឹងហើយ! ចាំអង្គាល់? ចម្លើយនាងឆ្លើយខ្លួនឯងក្នុងចិត្ត។

ស្រីស្អាតញញឹមជំនួសចម្លើយថា «Ok» ក្រោមពន្លឺភ្នែកនាយ ។ បានផលដល់ដៃប្រុសស្អាតប្រញាប់លូកទទួលយកវ៉ាលិស លើកដាក់សំដៅឃ្លុប។ វត្ថុមិនទាន់រុញចូលស៊ប់ផង កប៉ាល់ស្រាប់តែឃ្លោង។ គេបង្ហើយកម្លាំងចុងក្រោយប្រឆាំងនឹងសម្ពាធលំហ។

ទោះបីវ៉ាលិសបានចូលដល់ក្នុងឃ្លុបដោយសុវត្ថិភាពតែជំហរគេខ្លួនឯងមិនអាចទប់បាន១០០ភាគរយទេ។ ដូចក្នុងកុនរឿងស្នេហាលន្លង់លន្លោចដែរ ខាងប្រុសរេលកាយទៅប៉ះខាងស្រី រុញនាងឱ្យល្អៀងជំហរទាំងអស់គ្នា ហើយបើមិនយកដៃទៅត្រកងទប់ផងប្រុងដួលដេកលើគ្នាទាងថ្ងៃក្រទ្បេត។

ទៀតហើយ ដូចសំណាងស្នេហ៍បានមកពីព្រេង ស្មានថាត្រូវជិះម្នាក់ឯងស្ងាត់ស្ងៀមពីនេះដល់មេគង្គដឹងអី បានដៃគូមកកំដរហួសចិត្តរំពឹង ឯងនៅមិននៅ មកត្រូវគេត្រកងដោយឥតព្រាងទុកទៀត។

សុំទោស!

គេនិយាយតិចៗ ពេលនាងខំរលាស់ជំហរឈរត្រង់ឡើង ហើយថយជំហានចេញពីគេបន្តិច។

អារម្មណ៍ពេលនេះមិនបានដឹងសូម្បីតែកាប៊ីនរោទ៍ចេញចោលចំណត។ បើមិនមែនកប៉ាល់ធាក់ថយម៉េចបានប៉ះខាងស្រីយ៉ាងស្អិតមួយប៉ប្រិចភ្នែកមុននេះ?

ក្លិននាងនៅប្រហើរជាប់នាសានៅឡើយ ហើយទៅនឹកឃើញអីរឿងកាប៊ីនលាន់? ម៉ាស៊ីនយានទំនើបស្ងាត់ស្រាប់ផង មានអ្នកណាទៅចាប់អារម្មណ៍ភ្លាមៗ រហូតទាល់តែរាងកាយតូចដែលថយចេញនោះទ្រេតម្ដងទៀត ទើបគេនឹកឃើញ។

គេលោទៅរកទទួលនាងតែខាងស្រីរហ័សជាង នាងតោងបង្អែកកៅអីជាប់ ជាមួយកែវភ្នែកស្រទន់ស្នាមញញឹមតិចតួចល្មមបង្កើតភាពទន់ភ្លន់ឱ្យខាងប្រុសពេញមួយថ្ងៃបាន។

គេដកភ្នែកចេញពីនាងហើយទាញទូរសព្ទមករកចុច សាកសួរអ្នកខាងក្រៅ ជួនអីសារលោតមកភ្លាមៗ៖

«Kemal បក្សពួកពូឃីមមកដល់ភូមិចាមហើយ! យើងត្រូវចេញកប៉ាល់ភ្លាមឬអី?ខ្ញុំឱ្យគេរីយ៉ៃហើយ!»

Kemal ស្ទុះរឹងឱនសម្លឹងទៅក្រៅតាមបង្អួច ដោយដៃចុចភ្ជាប់ទូរសព្ទយ៉ាងរហ័សនឹងស្ទាត់ជំនាញបំផុត។ នៅលើច្រាំងនាយមិនបានប្រទះឃើញវត្ថុមានអង្គរក្សខ្លួនទៀតទេ។ គេស្ទុះមកច្រកត្រង់ដែលចម្ងាយប្រមាណជា៦ទៅ៧ម៉ែត្រប៉ុណ្ណោះពីទ្វារ ។ គ្រប់គ្នានៅទីនោះ ពួកគេឡើងមកដល់ទូកអស់ហើយ។

ស្របពេលខ្សែទូរសព្ទភ្ជាប់ ប្រុសស្អាតបញ្ជាខ្លីជាភាសាអង់គ្លេសៈ

Go!

ម៉ាស៊ីនរោទ៍មួយទំហឹង ស្របពេលកប៉ាល់ចាកចេញចោលច្រាំង។ ទឹកមុខស្មើធេងរបស់នាយបានបង្កើនសម្រស់បុរសភេទ ឱ្យខាងស្រីដែលបានតាមមើលចាប់ផ្តើមចេញចំហាយក្តៅឧណ្ហៗអៀនអន់ចាញ់ច្រាបទ្វេ។ ចំមែនហើយ! កំពុងតែលបមើលគេនិយាយទូរសព្ទ មិនស្មានថាគេនិយាយខ្លីត្រឹមមួយម៉ាត់ ស្រាប់តែដាក់វាចុះងាកមកវិញវឹប រកតែចោរស្រីដែលលួចគយគន់សម្រស់គេដកភ្នែកចេញលែងទាន់។ ម៉េចក៏ម៉េចទៅបើអ៊ីចឹងហើយ? នាងបណ្តោយឱ្យសរសៃចក្ខុប៉ះគ្នា ភ្ជាប់ចរន្តរមួល គាំងផ្អឹងកណ្តាលដែនវារី។

ប្រុសនេះមានភារកិច្ចបន្ទាន់ត្រូវធ្វើពិតណាស់ព្រោះគេចង់ទៅរកកូនចៅភ្លាមៗដោះស្រាយរឿងសំខាន់តែលុះមកឆក់ប៉ះព្រះអគ្គីនេត្រស្នេហ៍ គេរកដកភ្នែកវិញមិនកើតមានតែជំអក់នៅទីនោះ ឆក់គ្នាបន្តជាមួយនាង។

ទឹកមុខគេហាក់ដូចជា មនុស្សនេះទេវតាស្រាប់តែប្រទានមកភ្លាមៗសម្រាប់នាងតែម្តងហើយ។ គ្មានកន្លែងណាបង្ហាញថាគេមិនចាប់អារម្មណ៍នាង ឬថាចិត្តរំភើបមានតែម្ខាងនោះទេ។

នាងភ្លេចគិតសួរខ្លួនឯងថា ហេតុអ្វីកប៉ាល់ចេញទៅកើត បើទើបតែមានភ្ញៀវពីរនាក់ហ្នឹង?

«ពាក់ម៉ាសទៅ! មេរោគឆ្លងសាហាវណាស់!»

នាងនិយាយបន្ទប់ពេលដកខ្សែភ្នែកចេញពីគេទាំងសោកស្តាយ ហើយប្រឹងរកប្រធានបទផ្សេងមកបន្លប់។ ដៃខាងប្រុសទទួលយកម៉ាស ទាំងញឹមៗហើយលើកពាក់។

ខឹកៗ......

នាងរបូតសំណើច។

គឺនាងសើចទាំងពាក់ម៉ាស ក៏នាងនៅតែស្រស់ផូរផង់ដូចទេពធីតា។

ម៉េចហ្នឹង?

គេសួរពីរម៉ាត់ទាំងលើកចិញ្ចើមផងញញឹមរង់ចាំចម្លើយផង។ នារីអង្គុយក្បែរបាច់ផ្កាដែលស្រស់បំព្រង គ្រាន់តែបុស្បាហាក់រីកមិនត្រូវកន្លែង ហើយមកចាញ់សម្រស់ដ៏គត់មត់របស់នាង ។ នាងបន្តសើច ដោយងាកចេញធ្វើជាសម្លឹងផ្ទៃទឹកមិនឆ្លើយសំណួរខាងប្រុស។

បុរសងាកមុខសម្លឹងខ្លួនឯងតាមផ្ទាំងកញ្ចក់ពីក្រោយខ្នងស្រី។ គេអស់សំណើចតែខំទប់សើច។ ម៉ាស នេះមានរូបតុ្លកតុក្កតា បែរជានាងយកមកឱ្យខ្លួន ចំណែកម៉ាសលាតមិនមានរូបភាពគឺនៅលើមុខនាង ?

គេគិតទាំងក្នាញ់ រភ្នែកដៀងឌឺផង។ ដឹងចិត្តប្រុសស្អាត ស្រស់ស្រីខំពន្យល់វិញដោយសំឡេងស្រទន់ ៖

«ខ្ញុំមានម៉ាសតែពីរហ្នឹង! ភ្លេចគិតថា វារូបតុក្កតា!»

ភ្នែកនាងហាក់ដឹងកំហុសផង ហាក់ដូចជាបរិសុទ្ធមិនមានកំហុសដំណាលគ្នា បង្ខំខាងប្រុសញញឹម តបមុនផ្ទាន់ចម្លើយ៖

ម៉េចក៏បាន!

គេឆ្លើយតិចៗ ដូចជាសុភាពបុរសពីព្រេងនាយមកអ៊ីចឹង។

សុំទៅខាងណោះបន្តិច!

គេបន្ថែមហើយចាកចេញទៅរកទ្វារ។

នាងមិនតាមសម្លឹងទៀតទេខ្លាចគេងាកមកទាន់ទៀត។ ជម្រើសបែរទៅសម្លឹងផ្ទៃជលស័យ ដែលរត់ថយក្រោយជាគំនិតល្អហើយ តែចិត្តនេះវិញនៅតែរបិញ មុជមិនជ្រៅទៅមិនឆ្ងាយពីស្រមោលរវាងគ្នានឹងគ្នាឡើយ។

បើគេព្រមប្តូរម៉ាសជាមួយយើង យើងហ៊ានពាក់ដែរអត់ហ្ន៎?

ឆ្កួតហើយនាង! គេអាចមានកូវីដផងក៏ថាបាន! មិញប៉ះគ្នាមួយទំនង មានមេរោគហើយដឹងឯងនេះ?

ស្រីស្រស់គិតហើយ ប្រញាប់លូកក្នុងកាបូបតូចស្ពាយយកជែលអាកុលចេញមក។ ដៃលាងបណ្តើរ ងាកឃើញបាច់ផ្កាបណ្តើរ។ រឿងសំខាន់នឹងបន្ទាន់មួយបង្វិលគំនិតនាងមកវិញឱ្យចេញចោលពីភាពរាយមាយជាមួយវត្តមានប្រុសល្អ។

រឿងតែមួយគត់ដែលនារីមានក្នុងអារម្មណ៍នៅពេលនេះគឺ អូខេ ចេញពីភ្នំពេញបានហើយ! ទៅដល់ស្ទឹងត្រែងលែងមានបញ្ហាទៀតហើយ។ គ្រប់យ៉ាងរលូនហើយ!

ស្រីស្អាតដកដង្ហើមធូរទ្រូងជាងមុន ចាប់យកកាបូបលុយ ទូរស័ព្ទនិងកូនសោ មកលាងសម្អាតម្តងមួយៗ។

ក្លិនខ្លួនបុរសនេះវិលមកវិញក្បែរចម្រុះ។

គេមិនមែនមកឈរទេ អង្គុយកៀកគ្នា។

មិនមែនទេដឹង?

កៅអីមួយគរ? ខ្វះកន្លែងអង្គុយ?

នាងគិតទាំងប្រុងប្រយ័ត្នមិនងៀងភ្នែកទៅមើលគេដាច់ខាត តែកន្ទុយភ្នែកនាង បានក្បត់សម្បជញ្ញៈរបស់នាងហើយ។

ពីចំហៀង នាងដឹងថាគេពាក់ម៉ាសថ្មីហើយ គ្មានរូបតុក្កតាទៀតទេ។ ដៃគេកំពុងបត់ម៉ាសនាងទៅជាតូចៗ។ រួចហើយ....អូយ! គេដាក់វាទៅក្នុងហោប៉ៅ? ស្មានតែបោះធុងសំរាមនៅក្បែរជើង? រ៉ូមេនទិកម្ល៉េះ? លេងមែនទែនហើយហ្អី ? រក្សាទុកជាអនុស្សាវរីយ៍ទៀត?

នាងងាកមកសម្លឹងគេយឺតៗ។

ភ្នែកបុរសនេះចោលភាពអណ្តែតអណ្តូងមករកនាងមិនខ្លាចចិត្ត មិនខ្លាចខាងស្រីអៀន គឺនិយាយរួមគេនេះញ៉ែស្រីទាំងគ្មានសំឡេង និងមិនខ្លាចអ្វីទាំងអស់។

«Kemal»

គេស្រាប់តែនិយាយតិចៗពីរម៉ាត់នេះ។

ឃើញនាងគ្មានប្រតិកម្មអ្វី គេបន្ថែមមកទៀត៖

«ខ្ញុំឈ្មោះគីម៉ាល់!»

ឈ្មោះពីរោះដូចបរទេស។ នាងគិតទាំងព្រិចស្រទាប់រោមភ្នែកងរខ្មៅតទាំងសង។

«ហាន់ដា!»

មាណវីឆ្លើយស្រទន់ស្រាលៗ។

សម្រាប់នាយ តែម្ដង គឺគ្រប់ហើយ។ «ហាន់ដា» ឈ្មោះនេះចាក់ស្នាមភ្លាមៗក្នុងបេះដូងប្រុសកម្លោះ។ គេដៀងភ្នែកសម្លឹងនាងពីលើដល់ក្រោមព្រោះគេខ្ពស់ជាងនាងច្រើនហើយនៅកៀកជាឱកាសយ៉ាងក ម្រ។ ទោះយ៉ាងណាបាច់ផ្កា ញ៉ាំងអារម្មណ៍បុរសមិនស្រួលចិត្តទេ។ គេទើសទាល់ ហើយប្រែទឹកមុខ។ គេគិតច្រើន។

ហត្ថទាំងទ្វេលើកមកផ្ទឹបនឹងមាត់ លាក់បាំងភាពមិនស្កប់ចិត្ត។

សង្សារគេឱ្យផ្កាគេដឹង?

គេគិតហើយសៅហ្មងម្នាក់ឯងដោយមិនមានមូលហេតុ។

«ផ្កាស្អាតណាស់!»

ទ្រាំមិននិយាយមិនបានពេលចិត្តរកាំដោយក្ដីសង្ស័យ ។ ត្បិតតែប្រយោគខ្លីនេះលាន់តិចៗមកផ្ទាញ់ចិត្តនាងក៏ ហាន់ដាឆ្លាតល្មមនឹងយល់ចិត្តខាងប្រុស។ នាងរេភ្នែកសម្លឹងបាច់កុលាបក្រហមច្រាល។

ស្រីដាដៀងទៅសម្លឹងក៏ឃើញខាងប្រុសទម្លាក់ត្របកភ្នែកមើល ចុងដៃខ្លួនគេហាក់ទន្ទឹងរង់ចាំចម្លើយ។

«ទិញជូនម្ដាយខ្ញុំ! »

នាងនិយាយខ្លីតែស្នាមញញឹមគេវែង។ គេអរភេីតសារដើម ។ នាងនិយាយបន្ថែម៖

«ម្ដាយខ្ញុំគាត់កំពុងឈឺ ខ្ញុំទៅនេះទៅសួរសុខទុក្ខគាត់!»

«ស្ទឹងត្រែងឬក្រចេះ?!»

គេសួរសំណួរថ្មីដែលពញ្ញាក់ខាងស្រីឱ្យដឹងខ្លួនដូចខ្មោច៧ថ្ងៃ។ នាងដកខ្លួនឡើងសម្លឹងជុំវិញ។ត្រូវហើយ! ហេតុអីគ្មានអ្នកដំណើរ?

«ខ្ញុំច្រឡំទូកអត់ទេនៀក?»

នាងសួរទាំងសង្ស័យ។

បុរសមមីភ្នែកតាមគយគន់នាងទាំងមិនស្រដី។ នាងងាកសម្លឹងសារជាថ្មីហើយសំដៅទៅរកទ្វារ ដែលទៅនោះមនុស្សប្រុសពីរបីនាក់កំពុងមានវត្តមាននៅដោយឈរចរច្រប់ មិនទាំងហ៊ានអង្គុយចុះនៅឡើយ។

អ្វីមួយធ្វើឱ្យចិត្តកើតពិភាល់។

ស្រីស្អាតងាកមកវិញ ហើយសម្លឹងបុរសដែលធ្វើមិនដឹងរឿងក្បែរខ្លួនបង្កើយ។

«ខ្ញុំមិនមែនឡើងទូកExpressទេ?»

នាងនិយាយញ៉ៀវៗព្រោះបារម្ភហើយសំខាន់គ្មានមនុស្សស្រីផ្សេងម្នាក់ទាល់តែសោះ។

«ទាយទៅ?!» គេហាក់ឌឺដងសប្បាយពេលឃើញនាងអ៊ុំចឹង។

អារម្មណ៍រវើរវាយខាងស្នេហាក្នុងទ្រូងហាន់ដាបានរលាយដូចក្រមួនត្រូវភ្លើងសល់នូវភាពភ័យព្រួយដែលកំដរមកជាមួយគ្នាក្នុងវិនាទីនេះ។

ដៃស្រីក្ដោបម្រាមទាំងសងខាងធ្វើឱ្យខាងប្រុសនឹកអាណិតលែងចង់ធ្វើបាប។

គេវាចាស្រាលៗ ពីរោះពិសា៖

«កុំភ័យ! ខ្ញុំជូនដាដល់ផ្ទះ!»

នាងវេភ្នែកមករកគេ។ ចង់មិនចង់សម្ដីគេនាងជឿម្ល៉េះ។ ហាក់ដូចជាមានភាពសម្ងាត់មួយប្រាប់ហើយថា គេពិតជាធ្វើដូចដែលទើបនឹងបានសន្យា។ មិនធូរចិត្តច្រើនក៏ហាក់បានរសាយខ្លះ។ តូចតន់អង្គុយយឺតៗមកវិញ ហើយពិចារណាម្ដងបន្តិចៗមុនពេលសរុបគំនិតខ្លួនសួរទៅគេ៖

«ទូកឯកជន?»

បុរសដៀងភ្នែកមករកគូសន្ទនា ជាមួយពន្លឺភ្នែកដែលបង្កប់សវែងអន្លាយ មិនប៉ប្រិច។ ជាសញ្ញាថា «Yes!»។

ស្រីស្អាតធ្មេចភ្នែកយឺតៗបង្ហាញថានាង «ហួសចិត្ត» ខ្លាំង។

«ហើយម៉េច?»

គេសួរតិចៗ ពេលខាងស្រីមិនទាន់បើកភ្នែកមកវិញផង។ នាងតបតលឿនស្លេវហាក់ខឹងខ្លួនឯង ៖

«មានម៉េច! គឺខ្ញុំចង់សុំទោសតែនិយាយមិនចេញ! ចង់ខឹង មិនដឹងខឹងពីណា! ចង់ចុះ មិនដឹងចុះតាមណាហ្នឹងហើយ!»

ខឹកៗ គេសើចក្រអួនទ្រូង។

នាងបើកភ្នែក ដកដង្ហើមធំ ដៃរាវរកសំបុត្រទូកមកពិនិត្យមើល។

«ខ្ញុំអើយខ្ញុំ!»

«អត់អីទេ!»

បុរសនេះនិយាយស្រាលៗ ហើយដៀងភ្នែកសារជាថ្មីផ្តល់ភាពកក់ក្តៅឱ្យខាងស្រី។ គេនេះក្រៅពីចិត្តស្រាល ឆាប់សង្ស័យប្រចែប្រចណ្ឌ ចិត្តស្រើបឆាប់ចៃចង់ ថែមទាំងចេះបន្ទន់សំឡេងមួយបាវ១០០គីឡូទៀត។